## រោងម៉ាស៊ីនកិនស្រូវសហគមន៍ភ្នំដីររមៀល នាំមកនូវក្តីសង្ឃឹមថ្មីជូនកសិករ

សេដាក បានធ្វើការរៀបចំចងក្រងឱ្យមានជា**ជំនួញស្រូវសហគមន៍ ឬរោងម៉ាស៊ីនកិនស្រូវសហគមន៍** នៅដើមឆ្នាំ ២០០៨ ហើយបច្ចុប្បន្នមានរោងម៉ាស៊ីនកិនស្រូវសហគមន៍ចំនួន **២** បានសាងសង់រួចនៅក្នុងខេត្តតាកែវ និងកំពត។

នៅថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០០៩ នេះ សេដាក បានរៀបចំពិធីសម្ពោធ **រោងម៉ាស៊ីនកិនស្រូវសហគមន៍ភ្នំដីររមៀល** ស្ថិតនៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រុមការងារក្រសួងកសិកម្ម បុគ្គលិកអង្គការ សេដាក និងកសិករប្រមាណ ៣០០ នាក់បានចូលរួមនៅក្នុងពិធីនេះ។

ដោយមើលឃើញពីស្ថានភាពលក់ស្រូវរបស់កសិករទៅកាន់ទីផ្សារ និងទៅកាន់ឈ្មួញនានា ក្រោយពីប្រមូលផលស្រូវរួចជួបការលំបាក និងមិនមានតំលៃថ្លៃ ពិសេសតំលៃលក់របស់កសិករនៅតាមភូមិ នៅតែស្ថិតដាច់គ្នាឆ្ងាយពីការទិញ របស់ឈ្មួញឬរោងម៉ាស៊ីនធំៗនៅតាមតំបន់។ លើសពីនេះទៀត បន្ទាប់ពីកសិករធ្វើការលក់ស្រូវ (កសិករខ្លះលក់ស្ទើរអស់) នៅមានកសិករជាច្រើន ដែលត្រូវការទិញអង្ករសំរាប់យកមកហូបផងដែរ ហើយការទិញអង្កររបស់កសិករមានតំលៃថ្លៃ បើប្រៀបធៀបទៅនឹង តំលៃស្រូវរបស់កសិករដែលបានលក់ចេញ។ ហេតុដូចនេះហើយទើប សេដាកបានរៀបចំក្រុមកសិករដើម្បីធ្វើការលក់រួម-ទិញរួម ដោយបង្កើតជារោងម៉ាស៊ីនកិនស្រូវសហគមន៍ ដើម្បីធ្វើឱ្យការលក់ស្រូវ និងទិញអង្កររបស់ពួកគាត់មានតំលៃសមរម្យ។

នៅក្នុងពិធីនោះ បណ្ឌិតច័ន្ទ សារុន បានកោតសរសើរដល់អង្គការ សេដាក ចំពោះគំនិតផ្តួចផ្តើមនេះ ហើយបានជំរុញលើកទឹកចិត្តដល់កសិករឱ្យបង្កើតជា**សហគមន៍អភិវឌ្ឍន៍កសិកម្ម** ឱ្យបានច្រើនថែមទៀត ដោយបានប្រាប់ទៅដល់ក្រុមមន្ត្រីក្រោមឱវាទក្រសួងកសិកម្មទាំងអស់ ពិសេសមន្ទីកសិកម្មតាមបណ្តាខេត្តឱ្យជួយសំរួលក្នុងការចុះបញ្ជីជាផ្លូវការ។ លើសពីនេះ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា តាមរយៈរោងម៉ាស៊ីនកិនស្រូវសហគមន៍នេះ កសិករនឹង:

- អាចលក់ផលិតផលស្រូវរបស់ពួកគាត់បានថ្លៃ ព្រោះសហគមន៍ជាអ្នកកំណត់តំលៃ គឺខុសពីពេលមុន ដែលមានតែឈ្មួញឯកជនជាអ្នកកំណត់តំលៃ
- សន្តិសុខស្បៀងរបស់សហគមន៍ត្រូវបានធានាដោយសារមានស្រូវស្តុកនៅតាមមូលដ្ឋាន
- ងាយស្រួលក្នុងការទិញអង្ករដោយមិនមានការចំណាយលើការដឹកជញ្ជូន
- ងាយស្រួលចិញ្ចឹមសត្វ និងកែប្រែជីជាតិដី ( មានកន្ទក់និងអង្កាម)
- បង្កើតការងារដល់អ្នកភូមិ ដោយធ្វើការងារនៅក្នុងរោងម៉ាស៊ីន ជាពិសេសការទិញស្រូវនិងលក់អង្ករ
- សហគមន៍អាចទទួលបានប្រាក់ចំណូលសំរាប់ធ្វើការអភិវឌ្ឍន៍ និង
- យល់ដឹងបានច្រើនថែមទៀតអំពីព័តិមានទីផ្សារ ពិសេសតំរូវការទីផ្សារ។

គួរជំរាបជូនថា រោងម៉ាស៊ីនកិនស្រូវសហគមន៍ភ្នំដីររមៀលនេះ បានកសាងឡើងដោយចំណាយទឹកប្រាក់អស់ចំនួន

៤៦,000 ដុល្លាអាមេរិក ហើយអាចស្តុកស្រូវបាន ៤00 តោនស្រូវ និងមានសមត្ថភាពកិនស្រូវបាន ១ តោនក្នុង ១ ម៉ោង។ មកដល់ពេលនេះ គ្រួសារកសិករចំនួន ២៤១ គ្រួសារបានចូលជាសមាជិករបស់សហគមន៍រោងម៉ាស៊ីននេះ។

